ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩

## ជម្រើសផែនទីកសិកម្ម

June - July
Cambodia Inter-Censal Agriculture Survey 2019
For Economic Development of Cambodia

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សហការជាមួយ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខែ សីហា ២០២០

Food and Agriculture Organization of the United Nations
USAID FROM THE AMERICAN PEOPLE
BILL & MELINDA GATES foundation

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩

# ជម្រើសផែនទីកសិកម្ម

June - July
Cambodia Inter-Censal Agriculture Survey 2019
For Economic Development of Cambodia

វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ សហការជាមួយ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខែ សីហា ២០២០

Food and Agriculture Organization of the United Nations
USAID FROM THE AMERICAN PEOPLE
BILL & MELINDA GATES foundation

# មាតិកា


បុព្វកថា ... i

អារម្ភកថា ... v

បទបង្ហាញខ្លីស្តីពីវិធីសាស្ត្រអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា ឆ្នាំ ២០១៩ ... 2

១.គោលបំណង ... 2

២.វិសាលភាពនៃការអង្កេត ... 3

៣.ពេលវេលា និងកាលបរិច្ឆេទយោង ... 4

៤. សំណាក់គំរូ និងនីតិវិធីនៃការជ្រើសរើសគំរូ ... 4

៥.វិធីសាស្ត្រនៃធ្វើការអង្កេត និងប្រតិបត្តិការប្រមូលទិន្នន័យ ... 6

៦.ការដំណើរការទិន្នន័យ ... 7

៧.សេចក្តីសង្ខេបសូចនាករ ... 8

វិធីសាស្ត្រផលិតផែនទី ... 10

១.គោលបំណងនៃការផលិតផែនទី ... 10

២.ការវាយតម្លៃតពីផ្លូវការ ... 11

៣.វិធីសាស្ត្រសម្រាប់ការរចនាផែនទី ... 11

# បញ្ជីផែនទី


## ១. ស្ថានភាពគ្រួសារប្រកបរបរកសិកម្ម

ផែនទី ១.១: គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី) គិតជាភាគរយ បែងចែកតាមខេត្ត ..15

ផែនទី ១.២: គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (បានចុះបញ្ជី) គិតជាភាគរយ បែងចែកតាមខេត្ត .......17

## ២. ភាពជាម្ចាស់កម្មសិទ្ធិកសិដ្ឋានរបស់គ្រួសារប្រកបរបរកសិកម្ម

ផែនទី ២.១: កម្មសិទ្ធិដីផ្ទាល់ខ្លួននៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ....................21

ផែនទី ២.២: គ្រួសារប្រកបរបរកសិកម្មដែលបានជួលដីកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ....................23

## ៣. ផលិតកម្មដំណាំនៃគ្រួសារប្រកបរបរកសិកម្ម (រាប់ទាំងក្បាលដី និងដីជុំវិញផ្ទះ)

ផែនទី ៣.១: ផលិតកម្មស្រូវក្រអូបនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ....................27

ផែនទី ៣.២: អត្រាផ្ទៃដីបានប្រមូលផលធៀបនឹងផ្ទៃដីដាំដុះនៃស្រូវក្រអូប គិតជាភាគរយ បែងចែកតាមខេត្ត ....................29

ផែនទី ៣.៣: ទិន្នផលស្រូវក្រអូប គិតជាគីឡូក្រាម / ហិកតា បែងចែកតាមខេត្ត ....................31

ផែនទី ៣.៤: ផលិតកម្មស្រូវធម្មតានៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ....................33

ផែនទី ៣.៥: អត្រាផ្ទៃដីបានប្រមូលផលធៀបនឹងផ្ទៃដីដាំដុះនៃស្រូវធម្មតា គិតជាភាគរយ បែងចែកតាមខេត្ត ....................35

ផែនទី ៣.៦: ទិន្នផលស្រូវធម្មតា គិតជាគីឡូក្រាម / ហិកតា បែងចែកតាមខេត្ត ....................37

ផែនទី ៣.៧: ផលិតកម្មដំឡូងមីនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ....39

ផែនទី ៣.៨: ផលិតកម្មស្វាយចាន់ទីនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត....41

ផែនទី ៣.៩: ផលិតកម្មដូងនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ....43

ផែនទី ៣.១០: ផលិតកម្មកៅស៊ូនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ....45

ផែនទី ៣.១១: ផលិតកម្មចេកនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ....47

ផែនទី ៣.១២: ផលិតកម្មស្វាយនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ....49

## ៤. ផលិតកម្មចិញ្ចឹមបសុសត្វ និងបសុបក្សីនៃគ្រួសារប្រកបរបរកសិកម្ម

ផែនទី ៤.១: គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុសត្វប្រភេទធំ គិតជាភាគរយ បែងចែកតាមខេត្ត ....53

ផែនទី ៤.២: គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុសត្វប្រភេទតូច គិតជាភាគរយ បែងចែកតាមខេត្ត ....55

ផែនទី ៤.៣: គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុបក្សី គិតជាភាគរយ បែងចែកតាមខេត្ត....57

## ៥. វារីវប្បកម្ម និងនេសាទនៃគ្រួសារប្រកបរបរកសិកម្ម

ផែនទី ៥.១: គ្រួសារប្រកបរបរកសិកម្មមានកសកម្មភាពវារីវប្បកម្ម គិតជាភាគរយ បែងចែកតាមខេត្ត ....61

ផែនទី ៥.២: គ្រួសារប្រកបរបរកសិកម្មមានកសកម្មភាពនេសាទ គិតជាភាគរយ បែងចែកតាមខេត្ត....63

## ៦. គ្រួសារប្រកបរបរកសិកម្មមានគោលបំណងចម្បងៗសម្រាប់ផលិតផលកសិកម្ម

ផែនទី ៦.១: គ្រួសារប្រកបរបរកសិកម្មរាយការណ៍ពីផលិតកម្មកសិកម្មជាចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ គិតជាភាគរយ បែងចែកតាមខេត្ត ..... 67

ផែនទី ៦.២: គ្រួសារប្រកបរបរកសិកម្មរាយការណ៍ពីផលិតកម្មកសិកម្មជាចម្បងសម្រាប់លក់ គិតជាភាគរយ បែងចែកតាមខេត្ត ..... 69


## ៧. សេដ្ឋកិច្ច - សង្គមកិច្ច របស់គ្រួសារប្រកបរបរកសិកម្ម

ផែនទី ៧.១: គ្រួសារប្រកបរបរកសិកម្មបានប្រើប្រាស់សម្ភារៈក្នុងកសិដ្ឋានធ្វើការឲ្យអ្នកដ៏ទៃផ្សេងទៀត គិតជាភាគរយ បែងចែកតាមខេត្ត ..... 73

ផែនទី ៧.២: គ្រួសារប្រកបរបរកសិកម្មដែលមាន "ម៉ាស៊ីនកិនស្រូវ" គិតជាភាគរយ បែងចែកតាមខេត្ត ..... 75

ផែនទី ៧.៣: គ្រួសារប្រកបរបរកសិកម្មបានរងគ្រោះហានិភ័យយ៉ាងហោចណាស់ម្តង គិតជាភាគរយ បែងចែកតាមខេត្ត ..... 77

ផែនទី ៧.៤: គ្រួសារប្រកបរបរកសិកម្មបានរងគ្រោះហានិភ័យធ្ងន់ធ្ងរជាងឆ្នាំមុន គិតជាភាគរយ បែងចែកតាមខេត្ត ..... 79

ផែនទី ៧.៥: មេគ្រួសារប្រកបរបរកសិកម្មដែលជាស្ត្រី គិតជាភាគរយ បែងចែកតាមខេត្ត ..... 81


## ៨. គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ផែនទី ៨.១: កសិដ្ឋានខ្នាតតូច គិតជាភាគរយ បែងចែកតាមខេត្ត ..... 85

ផែនទី ៨.២: សូចនាករ គ.អ.ដ ២.៣.១ ផលិតភាពការងារជាមធ្យមរបស់អ្នកកាន់កសិដ្ឋានខ្នាតតូចក្នុងសមភាពអំណាចនៃការទិញ (PPP) គិតជាដុល្លា បែងចែកតាមខេត្ត ..... 87

## បញ្ជីតារាង

### ១. ស្ថានភាពគ្រួសារប្រកបរបរកសិកម្ម


តារាង ១.១: គ្រួសារប្រកបរបរកសិកម្មបានរាយការណ៍ឯកកម្មសិទ្ធ (មិនបានចុះបញ្ជី) ........ 16

តារាង ១.២: គ្រួសារប្រកបរបរកសិកម្មបានរាយការណ៍ឯកកម្មសិទ្ធ (បានចុះបញ្ជី) ........ 18


### ២. ភាពជាម្ចាស់កសិដ្ឋានរបស់គ្រួសារប្រកបរបរកសិកម្ម


តារាង ២.១: កម្មសិទ្ធិដីផ្ទាល់ខ្លួននៃគ្រួសារប្រកបរបរកសិកម្ម ........ 22

តារាង ២.២: គ្រួសារប្រកបរបរកសិកម្មដែលបានជួលដីកសិកម្ម ........ 24


### ៣. ផលិតកម្មដំណាំនៃគ្រួសារប្រកបរបរកសិកម្ម (រាប់ទាំងក្បាលដី & ដីជុំវិញផ្ទះ)


តារាង ៣.១: ផលិតកម្មស្រូវសរុបនៃគ្រួសារប្រកបរបរកសិកម្ម ........ 28

តារាង ៣.២: អត្រាផ្ទៃដីដែលបានប្រមូលផលធៀបនឹងផ្ទៃដីដាំដុះនៃស្រូវសរុប ........ 30

តារាង ៣.៣: គ្រួសារប្រកបរបរកសិកម្មទទួលបានទិន្នន័យផលស្រូវសរុប ........ 32

តារាង ៣.៤: ផលិតកម្មស្រូវវស្សានៃគ្រួសារប្រកបរបរកសិកម្ម ........ 34

តារាង ៣.៥: អត្រាផ្ទៃដីប្រមូលផលធៀបនឹងផ្ទៃដីដាំដុះនៃស្រូវវស្សា ........ 36

តារាង ៣.៦: គ្រួសារប្រកបរបរកសិកម្មទទួលបានទិន្នផលស្រូវវស្សា ........ 38

តារាង ៣.៧: ផលិតកម្មដំឡូងមីនៃគ្រួសារប្រកបរបរកសិកម្ម ........ 40
តារាង ៣.៨: ផលិតកម្មស្វាយចាន់ទីនៃគ្រួសារប្រកបរបរកសិកម្ម ........ 42
តារាង ៣.៩: គ្រួសារប្រកបរបរកសិកម្មមានផលិតកម្មដូង ........ 44
តារាង ៣.១០: គ្រួសារប្រកបរបរកសិកម្មមានផលិតកម្មកៅស៊ូ ........ 46
តារាង ៣.១១: គ្រួសារប្រកបរបរកសិកម្មមានផលិតកម្មចេក ........ 48
តារាង ៣.១២: គ្រួសារប្រកបរបរកសិកម្មមានផលិតកម្មស្វាយ ........ 50

## ៤. ផលិតកម្មចិញ្ចឹមបសុសត្វ នឹងបសុបក្សីនៃគ្រួសារប្រកបរបរកសិកម្ម

តារាង 4.១: គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុសត្វប្រភេទធំ ........ 54
តារាង ៤.២: គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុសត្វប្រភេទតូច ........ 56
តារាង ៤.៣: គ្រួសារប្រកបរបរកសិកម្មបានចិញ្ចឹមបសុបក្សី ........ 58

## ៥. វារីវប្បកម្ម នឹងនេសាទនៃគ្រួសារប្រកបរបរកសិកម្ម

តារាង ៥.១: គ្រួសារប្រកបរបរកសិកម្មមានសកម្មភាពវារីវប្បកម្ម ........ 62
តារាង ៥.២: គ្រួសារប្រកបរបរកសិកម្មមានសកម្មភាពនេសាទ ........ 64

## ៦. គ្រួសារប្រកបរបរកសិកម្មមានគោលបំណងចម្បងៗសម្រាប់ផលិតផលកសិកម្ម

តារាង ៦.១: គ្រួសារប្រកបរបរកសិកម្មរាយការណ៍ពីផលិតកម្មកសិកម្មជាចម្បងសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ........ 68

តារាង ៦.២: គ្រួសារប្រកបរបរកសិកម្មរាយការណ៍ពីផលិតកម្មកសិកម្មជាចម្បងសម្រាប់លក់ ........ 70


## ៧. សេដ្ឋកិច្ច - សង្គមកិច្ច របស់គ្រួសារប្រកបរបរកសិកម្ម

តារាង ៧.១: គ្រួសារប្រកបរបរកសិកម្មបានប្រើប្រាស់សម្ភារៈក្នុងកសិដ្ឋានធ្វើការឲ្យអ្នកដទៃផ្សេងទៀត ........ 74

តារាង ៧.២: គ្រួសារប្រកបរបរកសិកម្មដែលមាន “ម៉ាស៊ីនកិនស្រូវ” ........ 76

តារាង ៧.៣: គ្រួសារប្រកបរបរកសិកម្មបានរងគ្រោះហានិភ័យយ៉ាងហោចណាស់មួយ ........ 78

តារាង ៧.៤: គ្រួសារប្រកបរបរកសិកម្មបានរងគ្រោះហានិភ័យធ្ងន់ធ្ងរជាងឆ្នាំមុន ........ 80

តារាង ៧.៥: មេគ្រួសារប្រកបរបរកសិកម្មដែលជាស្ត្រី ........ 82


## ៨. គោលនយោបាយអភិវឌ្ឍន៍ប្រកបដោយចីរភាព

តារាង ៨.១: កសិដ្ឋានខ្នាតតូច ........ 86

តារាង ៨.២: សូចនាករ គ.អ.ដ ២.៣.១ ផលិតភាពការងារជាមធ្យមរបស់អ្នកកាន់កសិដ្ឋានខ្នាតតូចក្នុងសមភាពអំណាចនៃការទិញ (PPP) គិតជាដុល្លារ ........ 88

# មុខកថា

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានបង្ហាញនូវលទ្ធផលទិន្ន័យក្នុងផែនទីបានពីអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩ (CIAS2019) ។ ផែនទីទាំងនេះ គឺជាសមិទ្ធិផលថ្មីមួយទៀតបានពីកិច្ចខិតខំប្រឹងប្រែងចូលរួមក្នុងសកម្មភាពការងារយ៉ាងទូលំទូលាយពីសំណាក់មន្ត្រីជំនាញជាច្រើនដែលមានកិច្ចសហប្រតិបត្តិការល្អជំរឹងមាំ រវាងបណ្តាក្រសួងសាមីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់របស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងប្រជាជនកម្ពុជានៅក្នុងរាជធានី ខេត្តទាំង២៥ ។

អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ គឺជាសមិទ្ធិផលទិន្នន័យស្ថិតិកសិកម្មដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបង្ហាញឱ្យ យល់ដឹងកាន់តែច្បាស់អំពីស្ថានភាពកសិកម្ម បរិស្ថាន សេដ្ឋកិច្ច និងសង្គមគ្រួសារកសិកម្មកម្ពុជា និងព័ត៌មានដទៃទៀត សម្រាប់ជាធាតុចូលដ៏រឹងមាំក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការរៀបចំគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្មឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពល្អប្រសើរថែមទៀត។ របាយការណ៍វិភាគទិន្នន័យលើផែនទី ជួយបង្កលក្ខណៈងាយស្រួលបន្ថែមទៀត ដល់អ្នកប្រើប្រាស់ទិន្នន័យតាមរយៈផែនទីទាំងនេះ យើងរៀនក្នុងការស្វែងយល់អំពីស្ថានភាពស្របច្បាប់នៃគ្រួសារដែលកាន់កាប់កសិកម្ម កម្មសិទ្ធិ ការដាំដុះដំណាំ បសុសត្វ ឬវារីវប្បកម្ម នៅក្នុងរាជធានី-ខេត្តទាំង២៥ ស្ថានភាពងាយទទួលរងគ្រោះរបស់គ្រួសារកសិកម្ម និងភាគរយនៃគ្រួសារកសិកម្មដែលជាស្ត្រីនៅក្នុងខេត្តនីមួយៗ។ របាយការណ៍វិភាគទិន្នន័យលើផែនទី ក៏បានបង្ហាញនូវគ្រួសារកាន់កាប់កសិកម្មមានទំហំតូច និងអំពីផលិតភាពការងារ នៃអ្នកកាន់កាប់កសិកម្មខ្នាតតូច នៅតាមរាជធានី-ខេត្តផងដែរ ដើម្បីអនុវត្តន៍គាំទ្រសូចនាករដែលបានកំណត់ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ (ចំណុចដៅ ២.៣.១)។

ព័ត៌មានលម្អិតបន្ថែម នៅក្នុងតារាងទិន្នន័យ និងក្រាហ្វិចលើផែនទីនិមួយៗ ដែលបានភ្ជាប់ជាមួយ គឺមានបង្ហាញនៅក្នុងរបាយការណ៍វិភាគលទ្ធផលចុងក្រោយ នៃការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩។ ការចែករំលែកព័ត៌មានទិន្នន័យស្ថិតិកសិកម្មទាំងនេះ ក្នុងគោលបំណងដើម្បីឱ្យមានចំណាប់អារម្មណ៍កាន់តែខ្លាំងលើការវិនិយោគក្នុងសកម្មភាពការងារអង្កេតកសិកម្ម និងចូលរួមបង្កើនផលិតភាពក្នុងវិស័យកសិកម្មឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។ផែនទីទិន្នន័យអង្កេតនេះ នឹងផ្តល់អត្ថប្រយោជន៍សំខាន់យ៉ាងច្រើនដល់ការងារគ្រប់គ្រងដីធ្លី និងធនធាន សន្តិសុខស្បៀង ការរកបានប្រាក់ចំណូល និងផលិតភាពនៃកសិកម្ម និងរបរចិញ្ចឹមជីវិតរបស់ប្រជាជនកម្ពុជានៅក្នុងប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព។ ឯកសារផែនទីនេះជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ធ្វើការវាស់វែងត្រួតពិនិត្យ និងវាយតម្លៃអំពីការបម្រែបម្រួលស្ថានភាពវិស័យកសិកម្ម និងការប្រកបរបរចិញ្ចឹមជីវិតរបស់គ្រួសារកសិកម្មនៅតាមជនបទ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្តល់ការគាំទ្រក្នុងដំណើរការសកម្មភាពអង្កេតប្រមូល និងរៀបចំស្ថិតិទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ ដោយទទួលបានលទ្ធផលផ្លែផ្កា ប្រកបដោយគុណភាព ប្រសិទ្ធភាព ទាន់ពេលវេលាសម្រាប់បំពេញសេចក្តីត្រូវការប្រើប្រាស់របស់រាជរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ ។ ខ្ញុំសូមថ្លែងអរគុណដល់ វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ(FAO)ប្រចាំនៅកម្ពុជា ដែលបានចូលរួមជួយសម្របសម្រួលធ្វើសកម្មភាពការងារអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ រហូតដល់ទីបញ្ចប់ទទួលបានជោគជ័យជាស្ថាពរ។ ការងារគូសផែនទីបង្ហាញទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ គឺជាសកម្មភាពដ៏សំខាន់មួយមិនអាចខ្វះបានឡើយ ហើយចាំបាច់ត្រូវការសហប្រតិបត្តិការពីអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីទទួលបានព័ត៌មានអំពីគ្រួសារកសិកម្មទាំងអស់សម្រាប់គូសបង្ហាញលើផែនទី។ ខ្ញុំសូមថ្លែងអរគុណដល់ដៃគូអភិវឌ្ឍន៍អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ(FAO) និងទីភ្នាក់ងារ

សហប្រតិបត្តិការអន្តរជាតិសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍(USAID) ដែលបានជួយគាំទ្រផ្តល់មូលនិធិ និងជំនួយបច្ចេកទេស ដ៏មានសារសំខាន់បំផុតក្នុងការធ្វើសកម្មភាពចងក្រងទិន្នន័យស្ថិតិផែនទីបានដោយជោគជ័យ និងជួយពង្រឹងលើកកម្ពស់សមត្ថភាពមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តសកម្មភាព អង្កេតកសិកម្ម ឬអង្កេតដទៃទៀតស្រដៀងគ្នានេះនាពេលអនាគត ។

ទីបញ្ចប់ ខ្ញុំសូមថ្លែងអរគុណជាពិសេសចំពោះ **ឯកឧត្តម ហោ ដារិទ្ធ** រដ្ឋលេខាធិការក្រសួងផែនការ ទទួលបន្ទុកអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ និង **លោកជំទាវ ហង់ លីណា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ និងក្រុមការងារបច្ចេកទេសទាំងអស់ពីវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានដឹកនាំធ្វើសកម្មភាពអង្កេត និងវិភាគរបាយការណ៍លទ្ធផលទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ និងសូមអរគុណដល់អ្នកពាក់ព័ន្ធទាំងអស់ដែលបានរួមចំណែកក្នុងការផលិតផែនទីនេះឱ្យសម្រេចបានជោគជ័យប្រកបដោយគុណភាព ប្រសិទ្ធភាព និងទាន់ពេលវេលាសម្រាប់តម្រូវការចាំបាច់របស់អ្នកប្រើប្រាស់ដែលកើនឡើងជាលំដាប់។

ក្រសួងផែនការ

ភ្នំពេញ

ខែ វិច្ឆិកាឆ្នាំ ២០២០

**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន**
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

# អារម្ភកថា

នាងខ្ញុំមានសេចក្តីសោមនស្សរីករាយ ដោយបានបង្ហាញផែនទីទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ ដោយមានកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ពីអង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) សម្រាប់ចងក្រងឯកសារផែនទី ដើម្បីជាប្រយោជន៍ដល់អ្នករៀបចំផែនការ និងគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម បរិស្ថាន និងអ្នកស្រាវជ្រាវទាំងក្នុង និងក្រៅប្រទេស ឬរាជរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ។

ការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ គឺត្រូវបានធ្វើជាលើកដំបូងបន្ទាប់ពីបានធ្វើជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ២០១៣ ដើម្បីប្រមូលទិន្នន័យស្តីពីស្ថានភាព និងរចនាសម្ព័ន្ធ នៃវិស័យកសិកម្ម លក្ខណៈនៃសហគ្រាសកសិកម្មខ្នាតធំ និងផលិតកម្មកសិកម្មនៅទូទាំងប្រទេសកម្ពុជា សម្រាប់ជាមូលដ្ឋានគ្រឹះនិងជាតុចូលក្នុងការរៀបចំគោលនយោបាយអភិវឌ្ឍន៍ និងការពិនិត្យតាមដាន វាយតម្លៃលើផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជា។ ទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ ក៏ផ្តល់ជាឯកសារមូលដ្ឋានដ៏រឹងមាំសម្រាប់ការសិក្សាស្រាវជ្រាវគ្រប់កម្រិតដែលពាក់ព័ន្ធ និងស្ថានភាព សេដ្ឋកិច្ចសង្គម របស់គ្រួសារនៅតំបន់ទីជនបទនៃប្រទេសកម្ពុជាផងដែរ។ លើសពីនេះ ផែនទីទិន្នន័យទាំងអស់នេះ នឹងជួយបង្កើនការយល់ដឹងអំពីកសិកម្មកម្ពុជាដែលមាន សក្តានុពលលើយុទ្ធសាស្រ្តជាតិដើម្បីបង្កើនផលិតភាពនៃវិស័យកសិកម្ម ក្នុងការធានាបាននូវមុខរបរចិញ្ចឹមជីវិតនៅតាមទីជនបទប្រកប ដោយនិរន្តរភាពសន្តិសុខស្បៀង និងការការពារជាមូលដ្ឋានធនធានធម្មជាតិ សម្រាប់ពេលអនាគត ។

ការផលិតកម្រងទិន្នន័យផែនទីតាមប្រធានបទស្តីពីកសិកម្មកម្ពុជា គឺជាសមិទ្ធិផលដ៏មានសារសំខាន់មួយទៀតសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដោយបានបង្ហាញទិន្នន័យដែលមានផែនទី និងក្រាហ្វប្រមាណជាង ៣០ ដើម្បីឆ្លុះបញ្ចាំងអំពីស្ថានភាពស្របច្បាប់នៃគ្រួសារ

កាន់កាប់កសិកម្ម កម្មសិទ្ធិដីកសិកម្ម ទម្រង់ផលិតកម្ម ផ្ទៃដីសម្រាប់ធ្វើកសិកម្ម ឬការធ្វើវារីវប្បកម្ម គ្រោះហានិភ័យ និងកម្លាំងពលកម្មក្នុងវិស័យកសិកម្មនៅតាមរាជធានី ខេត្តនីមួយៗ ដោយផ្អែកលើសូចនាករគាំទ្រដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ។ ទិដ្ឋភាពលំហមួយចំនួនក្នុងការអង្កេតកសិកម្មនេះ ត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ដែលមានលក្ខណៈសាមញ្ញនៅក្នុងផែនទីតាមប្រធានបទដើម្បីធ្វើឱ្យកាន់តែងាយស្រួលយល់ដឹងអំពីទិន្នន័យស្ថិតិកសិកម្មនៅតាមរាជធានីដោយផ្អែកលើរបាយការណ៍លទ្ធផលចុងក្រោយនៃអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ ដែលគេអាចស្វែងយល់ស៊ីជម្រៅ និងលម្អិតអំពីរបាយការណ៍ទិន្នន័យទាំងនេះបាននៅក្នុងឯកសារបោះពុម្ពផ្សាយ និងតាមគេហទំព័ររបស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ។

ទីបញ្ចប់ នាងខ្ញុំសូមថ្លែងអរគុណចំពោះ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្តល់ការសហការគាំទ្រដល់ដំណើរការងារអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩ នេះ។ នាងខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តម លោក លោកស្រី ទាំងអស់ នៃក្រុមការងារស្នូលអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ មកពីវិទ្យាស្ថានជាតិស្ថិតិ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងលោក លោកស្រី ជំនាញការអង្គការស្បៀង និង កសិកម្មអង្គការសហប្រជាជាតិ (FAO) ព្រមទាំងមន្ត្រីទាំងអស់ ដែលបានចូលរួមអនុវត្តការងារប្រមូល វិភាគទិន្នន័យ ចងក្រងរបាយការណ៍ចុងក្រោយ របាយកាណ៍ផែនទីកសិកម្ម ឱ្យសម្រេចបានជោគជ័យ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

នាងខ្ញុំសូមផ្តល់អនុសាសន៍ថា៖ របាយការណ៍ផែនទីនេះ នឹងក្លាយជាធាតុចូលដ៏សំខាន់ក្នុងការរៀបចំកម្មវិធីគោលនយោបាយអភិវឌ្ឍន៍លើវិស័យកសិកម្មឱ្យកាន់តែមានគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ របាយការណ៍ផែនទីនេះ ត្រូវបានបើកចំហរសម្រាប់

*ពិភាក្សា ព្រមទាំងទទួលនូវរាល់មតិយោបល់ ឬអនុសាសន៍ សម្រាប់ការកែលម្អអភិវឌ្ឍន៍របាយការណ៍ លទ្ធផលវិភាគទិន្នន័យឱ្យកាន់តែល្អថែមទៀតនាពេលអនាគត ។*

**លោកជំទាវ ហង់ លីណា**

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយក**

**វិទ្យាស្ថានជាតិស្ថិតិ**

## បទបង្ហាញខ្លីស្តីពីវិធីសាស្ត្រអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា ឆ្នាំ ២០១៩[1]

ការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា(CIAS2019) នៅព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឡើងក្នុងឆ្នាំ២០១៩ គឺជាការអនុវត្តនូវប្រព័ន្ធស្ថិតិយ៉ាងទូលំទូលាយក្នុងការសម្ភាសន៍កត់ត្រា និងចងក្រងព័ត៌មានស្តីពី ការដាំដុះដំណាំ ការចិញ្ចឹមសត្វ បសុបក្សី វារីវប្បកម្ម និងនេសាទ។ លទ្ធផលទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា នឹងត្រូវបានប្រើសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច គោលនយោបាយ និងកម្មវិធីអភិវឌ្ឍកែលម្អលើវិស័យកសិកម្ម និងជលផលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ ត្រូវបានធ្វើជាលើកដំបូងដោយប្រើបច្ចេកវិទ្យាទំនើបម៉ាស៊ីន Tablets សម្រាប់ធ្វើសម្ភាសន៍កត់ត្រាទិន្នន័យ បន្ទាប់ពីជំរឿនកសិកម្មនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើឡើងលើកទីមួយនៅឆ្នាំ២០១៣។

វិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ បានសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាក្រសួងសាមីមានភារកិច្ចទទួលខុសត្រូវលើការអភិវឌ្ឍវិស័យកសិកម្ម ដែលបានអនុញ្ញាតដោយរាជរដ្ឋាភិបាលកម្ពុជា។ ទន្ទឹមនេះ វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ មានតួនាទី ភារកិច្ចក្នុងការធ្វើអង្កេត ចងក្រង វិភាគរបាយការណ៍លទ្ធផលទិន្នន័យអង្កេតកសិកម្ម រីឯក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាអ្នកប្រើទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ ។

### ១.គោលបំណង

គោលបំណងចម្បងរបស់ការអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ គឺដើម្បីផ្តល់ទិន្នន័យស្តីពីស្ថានភាពកសិកម្មនាពេលបច្ចុប្បន្នក្នុងព្រះរាជាណាចក្រកម្ពុជាដែលអ្នកធ្វើផែនការ និងអ្នកធ្វើគោលនយោបាយអាចយកទៅប្រើប្រាស់។ ដោយឡែកទិន្នន័យការសិក្សា

[1] ព័ត៌មានលម្អិតស្តីពីវិធីសាស្ត្រអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា ឆ្នាំ២០១៩ មានក្នុងរបាយការណ៍ចុងក្រោយអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា ឆ្នាំ ២០១៩ ។

អង្កេតចន្លោះជំរឿននេះនឹងមានសារៈប្រយោជន៍នៅក្នុង៖

១. ការផ្តល់ក្របខណ្ឌសំណាកគំរូបច្ចុប្បន្នភាពក្នុងការអនុវត្តការសិក្សាអង្កេតកសិកម្មផ្សេងៗ

២. ផ្តល់ទិន្នន័យនៅកម្រិតជាតិ និងកម្រិតតំបន់ ដោយមានទិន្នន័យមួយចំនួនមាននៅកម្រិតខេត្ត

៣. ផ្តល់ទិន្នន័យស្តីពីរចនាសម្ព័ន្ធបច្ចុប្បន្ននៃការកាន់កាប់កសិកម្មក្នុងប្រទេសកម្ពុជា រួមមាន ការដាំដំណាំ ការចិញ្ចឹមបសុសត្វ និងបសុបក្សី និងសកម្មភាពវារីវប្បកម្ម និងការនេសាទត្រី

## ៧.វិសាលភាពនៃការអង្កេត

ការអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ បានប្រើប្រាស់កម្រងសំណួរតែពីរទម្រង់ប៉ុណ្ណោះសម្រាប់កិច្ចខិតខំក្នុងការប្រមូលទិន្នន័យ ។ កម្រងសំណួរទាំងពីរគឺមាននៅក្នុងឯកសារភ្ជាប់ទី ២ នៃរបាយការណ៍នេះ។ កម្រងសំណួរទីមួយ គឺជាទម្រង់ការចុះបញ្ជីគ្រួសារដែលត្រូវបានប្រើប្រាស់ ដើម្បីប្រមូលព័ត៌មានកសិកម្មកម្រិតមូលដ្ឋានសម្រាប់គ្រប់គ្រួសារទាំងអស់នៅក្នុងមណ្ឌលអង្កេត EAs ដែលត្រូវបានជ្រើសរើសជាសំណាកគំរូ។ កម្រងសំណួរទីពីរដែលជាកម្រងសំណួរស្នូល សម្រាប់ការប្រមូលទិន្នន័យស្តីពីទិដ្ឋភាពទូទៅជាច្រើននៃការកាន់កាប់កសិកម្ម រួមទាំងព័ត៌មានប្រជាសាស្ត្រនៃម្ចាស់កាន់កាប់កសិកម្ម និងសហកម្មសិទ្ធិការកាន់កាប់ព្រមទាំងសមាជិកក្នុងគ្រួសារទាំងអស់ សកម្មភាពផលិតកម្មដំណាំ ការចិញ្ចឹមបសុសត្វ ការចិញ្ចឹមបសុបក្សី សកម្មភាពចិញ្ចឹមសត្វល្អិត សកម្មភាពវារីវប្បកម្ម សកម្មភាពនេសាទ សកម្មភាពសេដ្ឋកិច្ចផ្សេងទៀតក្នុងកសិដ្ឋានក្នុងអំឡុងរយៈពេល ១២ខែចុងក្រោយ កម្លាំងពលកម្មដែលត្រូវបានប្រើប្រាស់ដោយការកាន់កាប់កសិកម្ម និងព័ត៌មានស្តីពីលំនៅឋាន និងទ្រព្យសម្បត្តិរបស់គ្រួសារ ។

## ៣.ពេលវេលា និងកាលបរិច្ឆេទយោង

ការអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩ត្រូវបានធ្វើឡើងជាបីដំណាក់កាល៖ ដំណាក់កាលទី១គឺ ការចុះបញ្ជីគ្រួសារដើម្បីបង្កើតបញ្ជីគ្រួសារកាន់កាប់កសិកម្មទាំងអស់ក្នុង១៣៥០ មណ្ឌលអង្កេតសម្រាប់ជ្រើសរើសសំណាកគំរូលើគ្រួសារកាន់កាប់កសិកម្ម ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី ២៤ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៩។ ដំណាក់កាលទីពីរគឺ ការប្រតិបត្តិការណ៍សម្ភាសន៍លម្អិតលើគ្រួសារកាន់កាប់កសិកម្មបានធ្វើឡើងក្នុងអំឡុងរយៈពេលចាប់ពីថ្ងៃទី ៨ ដល់ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ ២០១៩ ។ ដំណាក់កាលទីបីគឺជាដំណាក់កាលចុងក្រោយនៃការប្រមូលទិន្នន័យគឺផ្តោតលើសហគ្រាសកសិកម្មខ្នាតធំ( ការកាន់កាប់កសិកម្មមិនជាគ្រួសារ) ធ្វើឡើងចាប់ពីថ្ងៃទី ២៤ ខែតុលា ដល់ថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ២០១៩ ។ ដោយបានប្រើរយៈពេល ១២ខែកន្លងមកគឺត្រូវបានកណត់យកពី ថ្ងៃទី ១ ខែកក្កដា ឆ្នាំ ២០១៨ ដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៩ គឺជាកាលបរិច្ឆេទយោងនៃការសម្ភាស ត្រូវបានប្រើប្រាស់ជាអំឡុងពេលសម្រាប់ការខិតខំប្រមូលទិន្នន័យ។

## ៤. សំណាក់គំរូ និងនីតិវិធីនៃការជ្រើសរើសគំរូ

បញ្ជីសំណាក (Sampling Frame) ជំរឿនកសិកម្ម ២០១៣ ដែលត្រូវបានប្រើប្រាស់ដើម្បីជ្រើសរើសសំណាកគំរូដែលមានចំនួនប្រមាណ ១៤០០០ ភូមិ និង ចំនួន ៣៥០០០ មណ្ឌលអង្កេត (EAs) ។ សម្រាប់ភូមិនីមួយៗគឺមានព័ត៌មានដូចខាងក្រោម៖ រាជធានី/ខេត្ត ក្រុង/ស្រុក ឃុំ/សង្កាត់ តំបន់ ទីប្រជុំជន/ជនបទ លេខរៀងមណ្ឌលអង្កេត EAs និងចំនួនសរុបគ្រួសារ។ គោលដៅជាសកលគឺសំដៅយកគ្រួសារទាំងឡាយណាដែលបានចូលរួមក្នុងសកម្មភាព កសិកម្មមានដូចជា៖ការដាំដុះដំណាំ ការចិញ្ចឹមបសុសត្វ បសុបក្សី វារីវប្បកម្ម និងការនេសាទ។

នីតិវិធីការជ្រើសរើសសំណាកគំរូដែលត្រូវបានយកមកប្រើគឺជាការជ្រើសរើសសំណាកគំរូពីរដំណាក់កាលដោយក្នុងនោះមាន ទីមួយ គឺការជ្រើសរើសមណ្ឌលអង្កេត EAs ហើយទីពីរ គឺការជ្រើសរើសគ្រួសារដែលចូលរួមក្នុងសកម្មភាពកសិកម្ម។ យើងបានសម្រេចចិត្តជ្រើសរើស មណ្ឌលអង្កេត EAs ចំនួន ១៣៥០ និងជ្រើសរើសការកាន់កាប់កសិកម្មចំនួន ១២គ្រួសារ សម្រាប់មណ្ឌលអង្កេត EA នីមួយៗ។ ទំហំសំណាកគំរូគ្រួសារកសិកម្មដែលបានគ្រោងទុកចំនួន ១៦០០០ គ្រួសារ។ មណ្ឌលអង្កេត EAs ចំនួន ១៣៥០ ត្រូវបានជ្រើសរើសសម្រាប់គ្រប់បណ្តាខេត្តទៅតាមសមាមាត្រទំហំ និងចំនួនគ្រួសារតាមតំបន់ទីជនបទ។ ដោយហេតុថា មិនមានភូមិជនបទក្នុងរាជធានីភ្នំពេញហេតុនេះមណ្ឌលអង្កេត EAs ចំនួន ៥០ ( ដែលស្មើនឹង ៦០ ០០០ គ្រួសារជនបទ) ដែលត្រូវបានជ្រើសរើសសម្រាប់រាជធានីភ្នំពេញតាមរូបមន្តដើម និង មណ្ឌលអង្កេត EAs ចំនួន ១៣២០ នោះត្រូវបានជ្រើសរើសទៅឱ្យខេត្តដទៃទៀតវិញ ។

គ្រួសារទាំងអស់នៅទូទាំងប្រទេសកម្ពុជាត្រូវមានសក្តានុពលអាចត្រូវបានជ្រើសរើសជាសំណាកដោយចៃដន្យពីការអង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ២០១៩នេះ លើកលែងតែគ្រួសារមានទីតាំងក្នុងខណ្ឌចំនួន ៦ ក្នុងរាជធានីភ្នំពេញ សង្កាត់មួយក្នុងខេត្តព្រះសីហនុ និងសង្កាត់មួយក្នុងខេត្តសៀមរាបដែលត្រូវបានស្គាល់ច្បាស់ថាជាតំបន់ទីប្រជុំជន។ គឺទំហំសំណាកគំរូសរុបចំនួន ១៣៥០ មណ្ឌលអង្កេត EAs ត្រូវបានជ្រើសរើសសម្រាប់ការសិក្សាអង្កេត ដោយក្នុងនោះសំណាកត្រូវបានជ្រើសរើសសម្រាប់ខេត្តនីមួយៗក្នុងប្រទេសកម្ពុជា រួមទាំងផ្នែកខ្លះក្នុងរាជធានីភ្នំពេញផងដែរ។ គ្រួសារសរុបចំនួន ១០១ ៣៨៣ គ្រួសារត្រូវបានទំនាក់ទំនងសាកសួរក្នុងដំណើរការចុះបញ្ជីគ្រួសារដែលបានជ្រើសរើសជាបឋម និងដើម្បីកំណត់អំពីសកម្មភាពផ្នែកកសិកម្ម។ សំណាកចំនួន ១៥ ៩៩៤ គ្រួសារកាន់កាប់កសិកម្មត្រូវបានជ្រើសរើសសម្រាប់ការសម្ភាសន៍ដោយប្រើប្រាស់តារាងសំណួរស្នូលនៃការអង្កេតនេះ ។

បន្ថែមលើកិច្ចខិតខំក្នុងការប្រមូលទិន្នន័យលើគ្រួសារកសិកម្ម យើងក៏បានប្រមូលទិន្នន័យដាច់ដោយឡែកមួយទៀតដោយផ្តោតលើសហគ្រាសកសិកម្មខ្នាតធំៗដែលប្រតិបត្តិការដោយ ក្រុមហ៊ុន សហគមន៍កសិកម្ម រដ្ឋាភិបាល និងស្ថាប័នឯកជនដែលយើងហៅថា "ការកាន់កាប់កសិកម្មមិនមែនជាគ្រួសារ" គឺបានប្រមូលទិន្នន័យពីវិស័យមិនមែនគ្រួសារនេះចំនួន ១៨៦ គ្រឹះស្ថាន ។

## ៥.វិធីសាស្ត្រនៃធ្វើការអង្កេត និងប្រតិបត្តិការប្រមូលទិន្នន័យ

ទិន្នន័យទាំងអស់ក្នុងការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា ត្រូវបានប្រមូលតាមរយៈការសម្ភាសផ្ទាល់ដោយមានជំនួយពីប្រព័ន្ធកុំព្យូទ័រ ធ្វើឡើងដោយក្រុមអ្នកស្រង់ទិន្នន័យដែលបានទទួលការបណ្តុះបណ្តាល និងអ្នកត្រួតពិនិត្យ ដែលសម្ភាសផ្ទាល់ជាមួយអ្នកឆ្លើយតបដែលមានការយល់ដឹងពីសហគ្រាសកសិកម្ម។ ការប្រើប្រាស់កម្មវិធី CAPI សម្រាប់ការប្រមូលទិន្នន័យ ជួយដល់ការពិនិត្យតាមដានលំហូរទិន្នន័យ និងគុណភាពទិន្នន័យទាន់ពេលវេលា។ អ្នកឆ្លើយតបគឺជាមនុស្សពេញវ័យដែលមានចំណេះដឹងពីសកម្មភាពរបស់សហគ្រាសកសិកម្ម។ អ្នកឆ្លើយតបដែលមានគុណវុឌ្ឍិបំផុតគឺម្ចាស់សហគ្រាសកសិកម្ម ប៉ុន្តែនៅពេលបុគ្គលទាំងនេះមិននៅ ប្តី/ប្រពន្ធ ឬសមាជិកគ្រួសារដែលមានការយល់ដឹង ក៏អាចធ្វើជាអ្នកតបសម្ភាសន៏ក៏បានដែរ។ គ្មានការសម្ភាស ឬសាកសួរអ្នកជិតខាង ឬគ្រួសារផ្សេងទៀតស្តីពីសហគ្រាសកសិកម្មដែលស្ថិតក្នុងការអង្កេតនេះឡើយ។

ទិន្នន័យទាំងអស់ពីការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា ត្រូវបានប្រមូលដោយអ្នកស្រង់ទិន្នន័យដែលបានទទួលការបណ្តុះបណ្តាល ដែលត្រូវបានជ្រើសរើសពីក្នុងចំណោមបុគ្គលិកថ្នាក់ជាតិ និងថ្នាក់ខេត្តនៃវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ប្រតិបត្តិការប្រមូលទិន្នន័យរួមមាន ការបណ្តុះបណ្តាលមន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យ និងមន្ត្រីប្រមូលទិន្នន័យ ទាំង

អស់ ។ មន្ត្រីថ្នាក់កណ្តាល និងមន្ត្រីសម្ភាសន៍នៅមូលដ្ឋាន មកពីវិទ្យាស្ថានជាតិស្ថិតិ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវបាន បណ្តុះបណ្តាល មុនពេលចុះប្រមូលទិន្នន័យ និងត្រួតពិនិត្យគុណភាពទិន្នន័យ។

មន្ត្រីត្រួតពិនិត្យគុណភាពទិន្នន័យដែលជាមន្ត្រីមកពីវិទ្យាស្ថានជាតិស្ថិតិ ដែលទទួលខុសត្រូវលើការពិនិត្យការគ្រប់គ្រងគុណភាព ទិន្នន័យ។ អ្នកត្រួតពិនិត្យតាមមូលដ្ឋានដែលមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងវិទ្យាស្ថានជាតិស្ថិតិ ទទួលខុសត្រូវលើការ ជួយដល់មន្ត្រីប្រមូលទិន្នន័យតាមមូលដ្ឋាន ដោយជំរុញឱ្យមានទំនាក់ទំនងល្អជាមួយអ្នកភូមិ និងបង្កើនកិច្ចសហប្រតិបត្តិការពីអ្នកតប សម្ភាសន៍ មកពីគ្រួសារកាន់កាប់កសិកម្ម។ មន្ត្រីសរុប ៤១៩ នាក់បានចូលរួមក្នុងការប្រមូលទិន្នន័យ ។

## ៦.ការដំណើរការទិន្នន័យ

នៅពេលមន្ត្រីសម្ភាសន៍ (ENU) បានប្រមូលទិន្នន័យសិក្សាអង្កេតសម្រាប់គ្រួសារកសិកម្មរួចហើយ គេបានផ្ញើរកម្រងសំណួរដែល បានបំពេញរួចនោះតាមរយៈកម្មវិធី survey solution មកកាន់មន្ត្រីត្រួតពិនិត្យទិន្នន័យ ដែលត្រូវអនុវត្តការត្រួតពិនិត្យលើកម្រងសំណួរ ដែលបានបំពេញរួចនោះ។ ប្រសិនបើមានកំហុស ឬពិនិត្យឃើញមានទិន្នន័យគួរឱ្យសង្ស័យ មន្ត្រីត្រួតពិនិត្យទិន្នន័យនឹងផ្ញើរត្រឡប់ទៅ វិញនូវកំណត់ត្រានោះទៅឲ្យមន្ត្រីសម្ភាសន៍ទិន្នន័យ ដើម្បីស្រាយចម្ងល់នោះ ជាមួយអ្នកផ្តល់ចម្លើយវិញប្រសិនបើចាំបាច់ ហើយកំណត់ ត្រាដែលបានកែតម្រូវរួច នឹងបានផ្ញើរជូនទៅកាន់មន្ត្រីត្រួតពិនិត្យទិន្នន័យវិញម្តងទៀត។ នៅពេលកំណត់ត្រាត្រូវបានផ្ទៀងផ្ទាត់ដោយ មន្ត្រីត្រួតពិនិត្យទិន្នន័យរួចហើយ ត្រូវផ្ញើរកំណត់ត្រានោះទៅមន្ត្រីថ្នាក់កណ្តាល ( HQ ) ដើម្បីស្នើសុំការឯកភាពជាចុងក្រោយ ។

សម្រាប់មន្ត្រីថ្នាក់កណ្តាលបន្ទាប់ពីទទួលបានកម្រងសំណួរបំពេញរួចផ្ញើរពីមន្ត្រីត្រួតពិនិត្យទិន្នន័យត្រូវពិនិត្យមើលជាចុងក្រោយ មុននឹងឯកភាពបញ្ជូន ប្រសិនបើមានបញ្ហា ឬមានទិន្នន័យគួរឱ្យសង្ស័យណាមួយត្រូវបានរកឃើញក្នុងអំឡុងពេលពិនិត្យឡើងវិញរបស់

មន្ត្រីថ្នាក់កណ្ដាលនេះ កំណត់ត្រានោះនឹងត្រូវផ្ញើរត្រឡប់ទៅមន្ត្រីសម្ភាសន៍វិញ ឬតាមរយៈមន្ត្រីត្រួតពិនិត្យទិន្នន័យដើម្បីផ្ទៀងផ្ទាត់ ឬកែតម្រូវប្រសិនបើចាំបាច់។ ឯកសារស្ដីពី របៀបពិនិត្យឡើងវិញលើទិន្នន័យក្នុងកម្រងសំណួរដើម្បីពិនិត្យរកចំណុចគួរជាទីសង្ស័យ ឬតួលេខមិនស្ថិតក្នុងវង្វង់ដែលបានកំណត់ គឺមានផ្ដល់ជូនទៅឲ្យមន្ត្រីត្រួតពិនិត្យទិន្នន័យ និងមន្ត្រីថ្នាក់កណ្ដាល។

ការពិនិត្យទិន្នន័យឡើងវិញ និងការគណនាតួលេខប៉ាន់ប្រមាណរបស់ការអង្កេតត្រូវបានធ្វើឡើងដោយប្រើប្រាស់ឧបករណ៍កម្មវិធីសហ្វវែរ RStudio ។ ការផ្ទៀងផ្ទាត់លើទិន្នន័យចាប់ផ្ដើមតាំងពីនៅពេលកម្រងសំណួរត្រូវបានបង្កើតតាក់តែងនៅក្នុងឧបករណ៍ CAPI ដោយហេតុថាកម្មវិធី Survey solution អនុញ្ញាតឲ្យមានការពិនិត្យយ៉ាងស៊ីសង្វាក់ ដើម្បីដាក់បញ្ចូលទៅក្នុងឧបករណ៍ប្រមូលទិន្នន័យ។ នៅពេលកំណត់ត្រាបំពេញរួចត្រូវបានបង្វិលត្រឡប់មកវិញក្នុងដំណាក់កាលប្រមូលទិន្នន័យ ការពិនិត្យលើភាពស៊ីសង្វាក់បន្ថែមទៀតត្រូវបានធ្វើឡើងដោយប្រៀបធៀបរបាយការណ៍ទៅនឹងទិន្នន័យជំរឿនកន្លងមក ដោយវាយតម្លៃលើលំដាប់នៃភាពសមហេតុផល សម្រាប់ចំណុចជាក់លាក់ និងផ្ទៀងផ្ទាត់លើតួលេខស្ថិតនៅក្រៅចន្លោះតួលេខដែលបានកំណត់ ជាមួយមន្ត្រីសម្ភាសន៍ និង/ឬអ្នកផ្ដល់ចម្លើយ។

## ៧.សេចក្ដីសង្ខេបសូចនាករ

ការប៉ាន់ស្មានសំខាន់ៗមួយចំនួនដែលទទួលបានពីការអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជា ឆ្នាំ ២០១៩ មានបង្ហាញក្នុងតារាងខាងក្រោម ៖

| | |
|---|---|
| ***សូចនាករសំខាន់ៗ៖ ការកាន់កាប់កសិកម្មតាមគ្រួសារ*** | |
| ចំនួនគ្រួសារកាន់កាប់កសិកម្ម | ១.៧២៦,៣៣៧ |
| ***ភាគរយនៃការកាន់កាប់កសិកម្មតាមគ្រួសារធ្វើកសិកម្មក្នុងគោលបំណងចម្បងសម្រាប់ ៖*** | |

| | |
|---|---|
| សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ | ៦១,១% |
| សម្រាប់លក់ | ៣៨,៩% |
| **សកម្មភាពផលិតកម្មដំណាំ** | |
| ចំនួនគ្រួសារដែលដាំដុះដំណាំ | ១.៥១៦,៩៦៧ |
| ភាគរយនៃគ្រួសារដាំដុះដំណាំ | ៨៧,៩% |
| **សកម្មភាពចិញ្ចឹមបសុសត្វ និង/ឬបសុបក្សី** | |
| ចំនួនគ្រួសារចិញ្ចឹមបសុសត្វ និង/ឬ បសុបក្សី និង/ឬ សត្វល្អិតនៅក្នុងអំឡុងពេលឆ្នាំយោង | ១.៣០០,៧២៥ |
| ភាគរយនៃគ្រួសារកសិកម្មបានចិញ្ចឹមបសុសត្វ និង/ឬ បសុបក្សី និង/ឬសត្វល្អិតនៅក្នុងអំឡុងពេលឆ្នាំយោង | ៧៥,៣% |
| **សកម្មភាពវារីវប្បកម្ម និងនេសាទ** | |
| ចំនួនគ្រួសារបានចូលរួមក្នុងសកម្មភាពវារីវប្បកម្ម និង/ឬ នេសាទ | ២៦៨.២៧៧ |
| ភាគរយនៃគ្រួសារចូលរួមក្នុងសកម្មភាពវារីវប្បកម្ម និង/ឬនេសាទ | ១៥,៥% |
| **ក្នុងចំណោមគ្រួសារបានចូលរួមសកម្មភាពវារីវប្បកម្ម និង/ឬនេសាទ** | |
| ភាគរយនៃគ្រួសារបានចូលរួមតែក្នុងសកម្មភាព វារីវប្បកម្ម ពីចំនួនគ្រួសារបានចូលរួមសកម្មភាពវារីវប្បកម្ម និង/ឬនេសាទ | ១២,៦% |
| ភាគរយនៃគ្រួសារបានចូលរួមតែក្នុងសកម្មភាពនេសាទ ពីចំនួនគ្រួសារបានចូលរួមសកម្មភាពវារីវប្បកម្ម និង/ឬនេសាទ | ៨០,៨% |
| ភាគរយនៃគ្រួសារបានចូលរួមទាំងពីរទាំងសកម្មភាពវារីវប្បកម្មជាមួយសកម្មភាពនេសាទនៃចំនួនគ្រួសារបានចូលរួមសកម្មភាពវារីវប្បកម្ម និង/ឬនេសាទ | ៦,៦% |

## វិធីសាស្ត្រផលិតផែនទី

### ១.គោលបំណងនៃការផលិតផែនទី

ការផលិតផែនទីចាប់ផ្តើមពីខែ កក្កដា រហូតដល់ខែ កញ្ញា ឆ្នាំ ២០២០ ក្រោយការបញ្ចប់វិភាគទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្ម កម្ពុជាឆ្នាំ ២០១៩ និងការសរសេររបាយការណ៍ចុងក្រោយបានបញ្ចប់។ សកម្មភាពនេះមានគោលបំណងផលិតកម្រងផែនទីតាមប្រធានបទ ដោយប្រើលទ្ធផលអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ បែងចែកតាមខេត្ត ដែលមានប្រយោជន៍ជាទីបំផុតចំពោះដៃគូរាជរដ្ឋាភិបាល។

ការផលិតផែនទីជាសូចនាករដែលពាក់ព័ន្ធនឹងកសិកម្មនៅថ្នាក់ជាតិ ត្រូវបានរំពឹងថានឹងផ្តល់ជាមូលដ្ឋានព័ត៌មានដល់ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ស្តីពីនិន្នាការ បត់បែន នៅកម្ពុជា និងជួយតម្រង់ទិញដល់ការធ្វើគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ផ្សេងៗ ។ គោលបំណងទីពីរគឺការបង្ហាញ និងផលិតផែនទីទៅតាមគោល សេដ្ឋកិច្ច សង្គមកិច្ច របស់កម្ពុជាក្នុងវិស័យកសិកម្ម ស្របតាម ទិន្នន័យដែលមានស្រាប់ ។

ការផលិតផែនទីណាមួយ មានជម្រើសជាច្រើន ដូចជា ជម្រើសមាត្រដ្ឋាន កម្រិត និងរយៈពេល ប្រធានបទ និងទិន្នន័យ (បែបបរិមាណ ឬគុណភាព) ការវិភាគ ការដំណើរការទិន្នន័យ និងវិធីសាស្ត្របង្ហាញ។ ឯកសារទាំងនេះនឹងពិពណ៌នាពីជម្រើសផ្សេងៗ និងមូលហេតុនៃការសម្រេចចិត្តយកមកផលិតជាផែនទី ។

## ២.ការវាយតម្លៃតម្រូវការ

អ្នកជំនាញ GIS ថ្នាក់ជាតិ បានសហការជាមួយអ្នកជំនាញមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង FAO ដើម្បីកំណត់រកវិធីសាស្ត្រសមស្របបំផុតសម្រាប់ការជ្រើសរើសផលិតផែនទីដែលមានប្រយោជន៍ និងពាក់ព័ន្ធបំផុត ហើយធ្វើការរៀបចំវិធីសាស្ត្រទាំងនោះ។ អ្នកជំនាញ GIS បានវាយតម្លៃតម្រូវការក្នុងកិច្ចប្រជុំជាមួយតំណាងរបស់ក្រសួងកសិកម្ម និងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីសម្រេចជាចុងក្រោយនៃកម្រងជាផែនទីតាមប្រធានបទឱ្យបានសមស្របបំផុត ។

## ៣.វិធីសាស្ត្រសម្រាប់ការរចនាផែនទី

ផែនទីតាមប្រធានបទ (Thematic Maps) អាចហៅថា ផែនទីសម្រាប់គោលបំណងពិសេស ផែនទីដែលផ្តោតលើប្រធានបទតែមួយ ឬផែនទីស្ថិតិ។ ផែនទីតាមប្រធានបទផ្តោតលើបម្រែបម្រួលលំហនៃរបាយ ឬប្រធានបទណាមួយ (ដូចជា ដំណាំ បសុសត្វ ឬផលធៀបនៃការលក់ និងការប្រើប្រាស់) ចំណែកផែនទីយោង ផ្តោតលើទីតាំង និងឈ្មោះនៃលក្ខណៈនានា។ ជាធម្មតា ផែនទីតាមប្រធានបទរួមបញ្ចូលព័ត៌មានទីតាំង ឬព័ត៌មានយោងមួយចំនួន ដូចជា ចំណងជើងផែនទី ឈ្មោះទីកន្លែង ឬផ្លូវទឹកសំខាន់ៗ មាត្រដ្ឋាន ព្រួញចង្អុលទិសខាងជើង និងសេចក្តីពន្យល់ ដើម្បីជួយឱ្យអ្នកមើលផែនទីយល់ពីតំបន់ភូមិសាស្ត្រនៅលើផែនទី។ ផែនទីតាមប្រធានបទទាំងអស់មានសមាសភាគសំខាន់ៗ ២ ៖ ផែនទីគោល និងទិន្នន័យស្ថិតិ។ សមាសភាគទាំង ២ ជាធម្មតា មានជាទម្រង់ឌីជីថល ដូចជា ទម្រង់ព្រំ-ប្រទល់ផែនទី និងទិន្នន័យជំរឿន ឬទិន្នន័យអង្កេត។

ផែនទីតាមប្រធានបទ មានបង្ហាញទិន្នន័យស្តីពីប្រធានបទដែលគួរមានចំណាប់អារម្មណ៍ ស្ថិតនៅក្នុងព្រំប្រទល់ជ្រើសរើសក្នុងតំបន់ភូមិសាស្ត្រមួយ ក្នុងករណីនេះគឺជាព្រំប្រទល់ខេត្ត។ ជាធម្មតា ទិន្នន័យទាំងនេះត្រូវបានចាត់ជាក្រុមទិន្នន័យដែលមានប្រភេទតម្លៃជាច្រើន និងសម្គាល់ដោយពណ៌ផ្សេងៗដើម្បីតំណាងឱ្យក្រុមប្រភេទនីមួយៗ ។ ផែនទីតាមប្រធានបទមានទម្រង់ជា រូបភាព ពណ៌ ដែលមានប្រសិទ្ធភាពសម្រាប់បង្ហាញពីទិន្នន័យសហគមន៍តាមបែបអព្ភន្តរញាណ ហើយជាពិសេសសម្រាប់អ្នកដែលមិនមានជំនាញក៏អាចមើលយល់បាន ។

ផែនទីអាចមើលយល់បានយ៉ាងលឿនពីបណ្តុំភូមិសាស្ត្រនៃគ្រួសារកសិកម្ម កសិកម្មសេដ្ឋកិច្ច ដំណាំ ព្រៃឈើ ជលផល ធនធានក្នុងសហគមន៍ ។ល។ តាមទីតាំងភូមិសាស្ត្រ សម្រាប់ជួយដល់ដំណើរការធ្វើផែនការរួមៗ ពេលមានផែនទីហើយ នោះយើងងាយស្រួលនឹងប្រើប្រាស់ផែនទីទាំងនេះឡើងវិញក្នុងទម្រង់ផ្សេងៗបាន ។ គេអាចបង្ហាញផែនទីក្នុងស្វាយ និងឯកសារបទបង្ហាញ ក្នុងការបោះពុម្ពផ្សាយ និងលើគេហទំព័រ។ ក្រៅពីនេះយើងអាចប្រើផែនទីជាជំនួយសម្រាប់បទបង្ហាញក្នុងកិច្ចប្រជុំសាធារណៈបានផងដែរ ។ ការប្រើផែនទីក្នុងកិច្ចប្រជុំសាធារណៈជួយឱ្យទស្សនិកជនយល់ពីទិន្នន័យបានយ៉ាងច្បាស់ តាមតំបន់គោលដៅ ដែលលើកឡើង និងតម្រូវការសហគមន៍ផ្សេងទៀតក្នុងទម្រង់ជារូបភាព ។

ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ជាកម្មវិធីកុំព្យូទ័រ ប្រើប្រាស់សម្រាប់បង្កើតផែនទីតាមប្រធានបទ។ ផែនទីដែលមានក្នុងរបាយការណ៍នេះ ត្រូវបានផលិតឡើងដោយកម្មវិធី QGIS (version 3.12) ជាកម្មវិធីដែលប្រើដោយមិនគិតថ្លៃ ។

- ***ប្រព័ន្ធអ័ក្ស និងកូអរដោនេ ៖*** *ផែនទីតាមប្រធានបទទាំងអស់ត្រូវបានផលិតឡើងតែនៅថ្នាក់ជាតិប៉ុណ្ណោះ ព្រោះការវិភាគទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ ធ្វើតែត្រឹមថ្នាក់ខេត្ត និងតាមតំបន់ភូមិសាស្ត្រតែប៉ុណ្ណោះ (មិនបានបង្ហាញរហូតដល់ ថ្នាក់ក្រោមជាតិទេ) ដោយប្រើប្រព័ន្ធកូអរដោនេគោលគឺ(*CRS*)* Indian 1960 / UTM zone 48N*។*
- ***ប្រភពទិន្នន័យព្រំប្រទល់ផែនទី:*** *ផែនទីតាមប្រធានបទទាំងអស់ត្រូវបានរៀបចំឡើងដោយប្រើប្រាស់ផែនទីគោលដូចៗគ្នាដែលបង្ហាញពីព្រំប្រទល់អន្តរជាតិ នឹងប្រទេសជិតខាង (រួមទាំងដែនកោះ) ព្រំប្រទល់ខេត្ត និងផ្លូវទឹក។ ផែនទីគោលទាំងនេះត្រូវបានផលិតឡើងដោយស្ថាប័នផ្លូវការ ដូចជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ និងវិទ្យាស្ថានជាតិស្ថិតិ (*NIS*)*[2]*។*
- ***ប្រភពទិន្នន័យសម្រាប់ផលិតផែនទីតាមប្រធានបទ:*** *រាល់ទិន្នន័យដែលបង្ហាញក្នុងផែនទីតាមប្រធានបទនេះ ប្រើប្រាស់តារាងទិន្នន័យបានមកពីការវិភាគទិន្នន័យអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩ ដោយគ្មានការកែប្រែ។*

---

[2] *ឈ្មោះជាភាសាអង់គ្លេសដែលបានប្រើប្រាស់បានមកពីបញ្ជីសម្រាប់ជ្រើសរើសសំណាក់គំរូ (*Sample frame*) ជំរឿនប្រជាជននៅកម្ពុជា ឬពីក្រសួងមហាផ្ទៃ។*

# ស្ថានភាពគ្រួសារប្រកបរបរកសិកម្ម

# ផែនទី ១.១: គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី) គិតជាភាគរយ បែងចែកតាមខេត្ត




ផែនទីនេះបង្ហាញថា គ្រួសារប្រកបរបរកសិកម្មភាគច្រើននៅកម្ពុជាបានរាយការណ៍ឯកកម្មសិទ្ធិ (មិនបានចុះបញ្ជី) ។ គ្រួសារប្រកបរបរកសិកម្មទាំងអស់នៅខេត្តស្ទឹងត្រែង បានរាយការណ៍ពីឯកកម្មសិទ្ធិមិនបានចុះបញ្ជី ។ ដោយឡែកនៅក្នុងខេត្តប៉ៃលិន មានតែ ២០% ប៉ុណ្ណោះ ។

ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩

**ការបដិសេធ**
ព្រំប្រទល់រដ្ឋបាល និងឈ្មោះដែលបានប្រើនៅក្នុងផែនទីនេះមិនបញ្ជាក់ពីការយល់ព្រម ឬការទទួលស្គាល់ជាផ្លូវការណាមួយរបស់អង្គការសហប្រជាជាតិឡើយ ។

*តារាង ១.១: គ្រួសារប្រកបរបរកសិកម្មបានរាយការណ៍ឯកកម្មសិទ្ធ (មិនបានចុះបញ្ជី)*

| កូដខេត្ត | ឈ្មោះខេត្ត | គ្រួសារប្រកបរបរកសិកម្មបានរាយការណ៍ឯកកម្មសិទ្ធ (មិនបានចុះបញ្ជី) | គ្រួសារប្រកបរបរកសិកម្មបានរាយការណ៍ឯកកម្មសិទ្ធ (មិនបានចុះបញ្ជី) (%) |
|---|---|---:|---:|
| ០១ | បន្ទាយមានជ័យ | ៧៧.៨០៨ | ៩៨,៧ |
| ០២ | បាត់ដំបង | ៨៩.១៣៩ | ៨៥,៩ |
| ០៣ | កំពង់ចាម | ៧៩.៧៩៤ | ៦៨,១ |
| ០៤ | កំពង់ឆ្នាំង | ៧៣.៣៧៧ | ៩០,៩ |
| ០៥ | កំពង់ស្ពឺ | ១១១.៣២៦ | ៨៤,២ |
| ០៦ | កំពង់ធំ | ៦៦.១៥៥ | ៥៥,៥ |
| ០៧ | កំពត | ៦៥.៨២៣ | ៦២,៩ |
| ០៨ | កណ្តាល | ៩៧.៨៨៦ | ៩១,៩ |
| ០៩ | កោះកុង | ៩.៧២២ | ៦៨,០ |
| ១០ | ក្រចេះ | ៣៣.៧៧៩ | ៧៩,៣ |
| ១១ | មណ្ឌលគីរី | ៧.៧៨៨ | ៨៣,៦ |
| ១២ | ភ្នំពេញ | ១៩.១១២ | ៩០,៧ |
| ១៣ | ព្រះវិហារ | ២៤.២៧៥ | ៧៦,៧ |
| ១៤ | ព្រៃវែង | ១៣៨.១៤២ | ៩៩,៧ |
| ១៥ | ពោធិ៍សាត់ | ៥៣.២៤៨ | ៨៩,៨ |
| ១៦ | រតនៈគីរី | ១៧.៦៥៩ | ៦២,៥ |
| ១៧ | សៀមរាប | ៨០.២២៣ | ៦៣,៦ |
| ១៨ | ព្រះសីហនុ | ១០.៨៩៧ | ៩៨,៨ |
| ១៩ | ស្ទឹងត្រែង | ១៥.០២៩ | ១០០,០ |
| ២០ | ស្វាយរៀង | ៨១.៨៣៨ | ៩១,៩ |
| ២១ | តាកែវ | ១៤០.២៣៨ | ៩៨,៨ |
| ២២ | ឧត្តរមានជ័យ | ១៦.៤៣៤ | ៤៥,៥ |
| ២៣ | កែប | ២.៧៦៦ | ៥៥,៤ |
| ២៤ | ប៉ៃលិន | ១.៣៤០ | ១៩,៦ |
| ២៥ | ត្បូងឃ្មុំ | ៧៤.០៦០ | ៧២,៤ |




ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ ២០១៩

# ផែនទី ១.២: គ្រួសារប្រកបរបរកសិកម្មដែលបានរាយការណ៍ឯកកម្មសិទ្ធិ (បានចុះបញ្ជី) គិតជាភាគរយ បែងចែកតាមខេត្ត




ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩

*តារាង ១.២: គ្រួសារប្រកបរបរកសិកម្មបានរាយការណ៍ឯកកម្មសិទ្ធ (បានចុះបញ្ជី)*

| កូដខេត្ត | ឈ្មោះខេត្ត | គ្រួសារប្រកបរបរកសិកម្មបានរាយការណ៍ឯកកម្មសិទ្ធ (បានចុះបញ្ជី) | គ្រួសារប្រកបរបរកសិកម្មបានរាយការណ៍ឯកកម្មសិទ្ធ (បានចុះបញ្ជី) (%) |
|---|---|---:|---:|
| ០១ | បន្ទាយមានជ័យ | ៨៨៧ | ១,១ |
| ០២ | បាត់ដំបង | ១៤.៤២៣ | ១៣,៩ |
| ០៣ | កំពង់ចាម | ៣៧.១០០ | ៣១,៧ |
| ០៤ | កំពង់ឆ្នាំង | ៧.១៧៦ | ៨,៩ |
| ០៥ | កំពង់ស្ពឺ | ២១.២៣៨ | ១៥,៥ |
| ០៦ | កំពង់ធំ | ៥១.៧៨០ | ៤៣,៤ |
| ០៧ | កំពត | ៣៨.៦៤៧ | ៣៦,៩ |
| ០៨ | កណ្ដាល | ៨.៣៨១ | ៧,៩ |
| ០៩ | កោះកុង | ៤.៥៦៥ | ៣២,០ |
| ១០ | ក្រចេះ | ៨.៧៥៦ | ២០,៦ |
| ១១ | មណ្ឌលគីរី | ១.៥២៧ | ១៦,៤ |
| ១២ | ភ្នំពេញ | ១.៩៥៣ | ៩,៣ |
| ១៣ | ព្រះវិហារ | ៧.៣៩១ | ២៣,៣ |
| ១៤ | ព្រៃវែង | ៤០៥ | ០,៣ |
| ១៥ | ពោធិ៍សាត់ | ៥.៤៩៥ | ៩,៣ |
| ១៦ | រតនៈគីរី | ១០.៥៧២ | ៣៧,៤ |
| ១៧ | សៀមរាប | ៤៥.០០៨ | ៣៥,៧ |
| ១៨ | ព្រះសីហនុ | ៨១ | ០,៧ |
| ១៩ | ស្ទឹងត្រែង | ០ | ០,០ |
| ២០ | ស្វាយរៀង | ៧.១៩០ | ៨,១ |
| ២១ | តាកែវ | ១.៤១២ | ១,០ |
| ២២ | ឧត្តរមានជ័យ | ១៩.១៥៩ | ៥៣,០ |
| ២៣ | កែប | ២.២០០ | ៤៤,០ |
| ២៤ | ប៉ៃលិន | ៥.៤៩១ | ៨០,៤ |
| ២៥ | ត្បូងឃ្មុំ | ២៧.៣៤០ | ២៦,៧ |




ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ ២០១៩

# ភាពជាម្ចាស់កម្មសិទ្ធកសិដ្ឋានរបស់គ្រួសារប្រកបរបរកសិកម្ម

# ផែនទី ២.១: កម្មសិទ្ធិដីផ្ទាល់ខ្លួននៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត

កម្ពុជា
ចំនួនគ្រួសារប្រកបរបរកសិកម្មសរុប : ១.៧២៦.៣៣៧
ភាគរយគ្រួសារប្រកបរបរកសិកម្ម
មានកម្មសិទ្ធិដីផ្ទាល់ខ្លួន : ៩៨,១%

ដីគ្រួសារប្រកបរបរកសិកម្មស្ទើរតែទាំងអស់នៅកម្ពុជា មានកម្មសិទ្ធិដីផ្ទាល់ខ្លួន ។ ភាគរយទាបបំផុតនៃកម្មសិទ្ធិដីផ្ទាល់ខ្លួនមាននៅក្នុងខេត្តប៉ៃលិន ដោយឡែក ភាគរយខ្ពស់បំផុតមាននៅក្នុងខេត្តកំពត ។ វាហាក់ដូចជានិន្នាការមួយនៅក្នុងប្រទេសកម្ពុជាដែលមានខេត្តភាគខាងលិចភាគច្រើន មិនមានកម្មសិទ្ធិដីផ្ទាល់ខ្លួន ដោយឡែកខេត្តភាគខាងកើត ភាគច្រើនមានអត្រាកម្មសិទ្ធិដីផ្ទាល់ខ្លួនខ្ពស់ ។




ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩

**ការបដិសេធ**
ព្រំប្រទល់រដ្ឋបាល និងឈ្មោះដែលបានប្រើនៅក្នុងផែនទីនេះមិនបញ្ជាក់ពីការយល់ព្រម ឬការទទួលស្គាល់ជាផ្លូវការណាមួយរបស់អង្គការសហប្រជាជាតិឡើយ ។

*តារាង ២.១: កម្មសិទ្ធិដីផ្ទាល់ខ្លួននៃគ្រួសារប្រកបរបរកសិកម្ម*

| កូដខេត្ត | ឈ្មោះខេត្ត | កម្មសិទ្ធិដីផ្ទាល់ខ្លួននៃគ្រួសារប្រកបរបរកសិកម្ម | កម្មសិទ្ធិដីផ្ទាល់ខ្លួននៃគ្រួសារប្រកបរបរកសិកម្ម (%) |
|---|---|---:|---:|
| ០១ | បន្ទាយមានជ័យ | ៧៧.៩៧១ | ៩៨,៩ |
| ០២ | បាត់ដំបង | ៩៧.៩៣៩ | ៩៤,៣ |
| ០៣ | កំពង់ចាម | ១១៦.៣៤៨ | ៩៩,៣ |
| ០៤ | កំពង់ឆ្នាំង | ៨០.០៦៣ | ៩៩,២ |
| ០៥ | កំពង់ស្ពឺ | ១៣៦.៤២៥ | ៩៩,៦ |
| ០៦ | កំពង់ធំ | ១១៨.៤០០ | ៩៩,៣ |
| ០៧ | កំពត | ១០៤.២៦៩ | ៩៩,៧ |
| ០៨ | កណ្ដាល | ១០១.៥០៤ | ៩៥,៣ |
| ០៩ | កោះកុង | ១៣.២៣២ | ៩២,៦ |
| ១០ | ក្រចេះ | ៤២.៣៧១ | ៩៩,៥ |
| ១១ | មណ្ឌលគីរី | ៩.០៩០ | ៩៧,៦ |
| ១២ | ភ្នំពេញ | ១៩.៦៣៩ | ៩៣,២ |
| ១៣ | ព្រះវិហារ | ៣១.៣៦៤ | ៩៩,០ |
| ១៤ | ព្រៃវែង | ១៣៧.៨១៤ | ៩៩,៥ |
| ១៥ | ពោធិ៍សាត់ | ៥៧.៧៣៣ | ៩៧,៣ |
| ១៦ | រតនៈគីរី | ២៧.៣៥០ | ៩៦,៨ |
| ១៧ | សៀមរាប | ១២.០៩៩ | ៩៦,០ |
| ១៨ | ព្រះសីហនុ | ១០.៩២០ | ៩៩,០ |
| ១៩ | ស្ទឹងត្រែង | ១៤.៧៦៤ | ៩៨,២ |
| ២០ | ស្វាយរៀង | ៨៨.៦៤៥ | ៩៩,៦ |
| ២១ | តាកែវ | ១៤១.២៣០ | ៩៩,៥ |
| ២២ | ឧត្តមានជ័យ | ៣៤.៧៣៥ | ៩៦,២ |
| ២៣ | កែប | ៤.៨២៣ | ៩៦,៥ |
| ២៤ | ប៉ៃលិន | ៦.១០៨ | ៨៩,៤ |
| ២៥ | ត្បូងឃ្មុំ | ៩៨.៦៧៧ | ៩៦,៧ |




ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ ២០១៩

# ផែនទី ២.២: គ្រួសារប្រកបរបរកសិកម្មដែលបានជួលដីកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត

កម្ពុជា

គ្រួសារប្រកបរបរកសិកម្មសរុប : ១.៧២៦.៣៣៧

ភាគរយគ្រួសារប្រកបរបរកសិកម្ម
ដែលបានជួលដីកសិកម្ម : ៤,១%




តិចជាង ៥% នៃគ្រួសារប្រកបរបរកសិកម្មទាំងអស់នៅកម្ពុជា បានជួលដីកសិកម្មពីអ្នកដទៃ។ គ្រួសារដែលបានជួលដីកសិកម្មភាគច្រើននៅភាគខាងលិច គឺមានអត្រារហូតដល់ ១០% នៅខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង ។

ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩

**ការបដិសេធ**

ព្រំប្រទល់រដ្ឋបាល និងឈ្មោះដែលបានប្រើនៅក្នុងផែនទីនេះមិនបញ្ជាក់ពីការយល់ព្រម ឬការទទួលស្គាល់ជាផ្លូវការណាមួយរបស់អង្គការសហប្រជាជាតិឡើយ ។

### តារាង ២.២: គ្រួសារប្រកបរបរកសិកម្មដែលបានជួលដីកសិកម្ម

| កូដខេត្ត | ឈ្មោះខេត្ត | គ្រួសារប្រកបរបរកសិកម្ម ដែលបានជួលដីកសិកម្ម | គ្រួសារប្រកបរបរកសិកម្មដែល បានជួលដីកសិកម្ម(%) |
|---|---|---|---|
| ០១ | បន្ទាយមានជ័យ | ៤.៣៣៣ | ៥,៥ |
| ០២ | បាត់ដំបង | ១៦.២៣៧ | ១៥,៦ |
| ០៣ | កំពង់ចាម | ២.០៧៧ | ១,៨ |
| ០៤ | កំពង់ឆ្នាំង | ១.០៧២ | ១,៣ |
| ០៥ | កំពង់ស្ពឺ | ១.១៦៩ | ០,៩ |
| ០៦ | កំពង់ធំ | ១.៥៤៥ | ១,៣ |
| ០៧ | កំពត | ៦០៨ | ០,៦ |
| ០៨ | កណ្ដាល | ៦.៧០៣ | ៦,៣ |
| ០៩ | កោះកុង | ១.១៦៤ | ៨,១ |
| ១០ | ក្រចេះ | ២៦៤ | ០,៦ |
| ១១ | មណ្ឌលគីរី | ១៨៩ | ២,០ |
| ១២ | ភ្នំពេញ | ៦៥២ | ៣,១ |
| ១៣ | ព្រះវិហារ | ១៩៤ | ០,៦ |
| ១៤ | ព្រៃវែង | ៦.៧៣៧ | ៤,៩ |
| ១៥ | ពោធិ៍សាត់ | ៣.៤៧៩ | ៥,៩ |
| ១៦ | រតនៈគីរី | ១.៧៦៤ | ៦,២ |
| ១៧ | សៀមរាប | ៩.៤៧២ | ៧,៥ |
| ១៨ | ព្រះសីហនុ | ១៦ | ០,១ |
| ១៩ | ស្ទឹងត្រែង | ៩៨ | ០,៧ |
| ២០ | ស្វាយរៀង | ៣.៤៦៤ | ៣,៩ |
| ២១ | តាកែវ | ១.៥១៤ | ១,១ |
| ២២ | ឧត្ដរមានជ័យ | ៣.៩០៧ | ១០,៨ |
| ២៣ | កែប | ០ | ០,០ |
| ២៤ | ប៉ៃលិន | ៣៣៩ | ៥,០ |
| ២៥ | ត្បូងឃ្មុំ | ៣.០២៧ | ៣,០ |




ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ ២០១៩

# ផលិតកម្មដំណាំនៃគ្រួសារប្រកបរបរកសិកម្ម

## ( រាប់ទាំងក្បាលដី និង ដីជុំវិញផ្ទះ )

# ផែនទី ៣.១: ផលិតកម្មស្រូវក្រអូបនៃគ្រួសារប្រកបរបរកសិកម្ម គិតជាភាគរយ បែងចែកតាមខេត្ត

**កម្ពុជា**

គ្រួសារប្រកបរបរកសិកម្មសរុប : ១.៧២៦.៣៣៧

ភាគរយគ្រួសារប្រកបរបរកសិកម្មមានផលិតកម្មស្រូវក្រអូប : ១៣,១%




មានតែ ១៣,១% នៃគ្រួសារប្រកបរបរកសិកម្មនៅកម្ពុជា បានចូលរួមក្នុងផលិតកម្មស្រូវក្រអូប។ គ្រួសារប្រកបរបរកសិកម្មនៅខេត្តភាគពាយព្យ មានភាគរយ ខ្ពស់បំផុតនៃផលិតកម្មស្រូវក្រអូប ដល់ទៅ ៣១,២% នៅខេត្តបន្ទាយមានជ័យ។ ដោយឡែកនៅខេត្តប៉ៃលិន និងខេត្តព្រះសីហនុ មិនមានផលិតកម្មស្រូវក្រអូបទេ ។

**កំណត់សម្គាល់**

- ផ្ទៃទឹក

ផលិតកម្មស្រូវក្រអូបនៃគ្រួសារប្រកបរបរកសិកម្ម (%)

- ≤ ៥,០
- ៥,១ - ១០,០
- ១០,១ - ១៥,០
- ១៥,១ - ២៥,០
- > ២៥,០

ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩

**ការបដិសេធ**

ព្រំប្រទល់រដ្ឋបាល និងឈ្មោះដែលបានប្រើនៅក្នុងផែនទីនេះមិនបញ្ជាក់ពីការយល់ព្រម ឬការទទួលស្គាល់ជាផ្លូវការណាមួយរបស់អង្គការសហប្រជាជាតិឡើយ ។

*តារាង ៣.១: ផលិតកម្មស្រូវក្រអូបនៃគ្រួសារប្រកបរបរកសិកម្ម*

| កូដខេត្ត | ឈ្មោះខេត្ត | ផលិតកម្មស្រូវក្រអូបនៃគ្រួសារប្រកបរបរកសិកម្ម | ផលិតកម្មស្រូវក្រអូបនៃគ្រួសារប្រកបរបរកសិកម្ម (%) |
|---|---|---:|---:|
| ០១ | បន្ទាយមានជ័យ | ២៤.៥៧៧ | ៣១,២ |
| ០២ | បាត់ដំបង | ២៦.៤០៩ | ២៥,៤ |
| ០៣ | កំពង់ចាម | ៩.៣១៧ | ៨,០ |
| ០៤ | កំពង់ឆ្នាំង | ១៦.២៩៣ | ២០,២ |
| ០៥ | កំពង់ស្ពឺ | ១៨.៩៥២ | ១៣,៨ |
| ០៦ | កំពង់ធំ | ១៤.១៦១ | ១១,៩ |
| ០៧ | កំពត | ៨.៧៦៦ | ៨,៤ |
| ០៨ | កណ្តាល | ១៦២ | ០,២ |
| ០៩ | កោះកុង | ២០៤ | ១,៤ |
| ១០ | ក្រចេះ | ១.៩២០ | ៤,៥ |
| ១១ | មណ្ឌលគិរី | ១២ | ០,១ |
| ១២ | ភ្នំពេញ | ៣៣៩ | ១,៦ |
| ១៣ | ព្រះវិហារ | ៧.៣៩៧ | ២៣,៤ |
| ១៤ | ព្រៃវែង | ២៧.៩៤៤ | ២០,២ |
| ១៥ | ពោធិ៍សាត់ | ១០.៧២៤ | ១៨,១ |
| ១៦ | រតនៈគិរី | ៤៥៤ | ១,៦ |
| ១៧ | សៀមរាប | ២៤.៥៨៥ | ១៩,៥ |
| ១៨ | ព្រះសីហនុ | ០ | ០,០ |
| ១៩ | ស្ទឹងត្រែង | ១៥៣ | ១,០ |
| ២០ | ស្វាយរៀង | ៦.៥៣២ | ៧,៣ |
| ២១ | តាកែវ | ១៤.៨១៥ | ១០,៤ |
| ២២ | ឧត្តរមានជ័យ | ៨.៦៩០ | ២៤,១ |
| ២៣ | កែប | ៩១ | ១,៨ |
| ២៤ | ប៉ៃលិន | ០ | ០,០ |
| ២៥ | ត្បូងឃ្មុំ | ៣.៥៧៩ | ៣,៥ |




ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ ២០១៩

# ផែនទី ៣.២: អត្រាផ្ទៃដីបានប្រមូលផលធៀបនឹងផ្ទៃដីដាំដុះនៃស្រូវក្រអូប គិតជាភាគរយ បែងចែកតាមខេត្ត

**កម្ពុជា**

| | |
|---|---|
| គ្រួសារប្រកបរបរកសិកម្មសរុប | : ១.៧២៦,៣៣៧ |
| ចំនួនគ្រួសារប្រកបរបរកសិកម្មបានដាំដុះស្រូវក្រអូប | |
| ក្រឡាផ្ទៃប្រមូលផល / ក្រឡាផ្ទៃដាំដុះ (x ១០០) | : ៩៤,៨ |




ស្ទើរតែទាំងអស់នៃផ្ទៃដាំដុះដំណាំស្រូវក្រអូប ត្រូវបានប្រមូលផលក្នុងកំឡុងការីបរិច្ឆេទយោង។ មានខេត្តចំនួន ៦ (កណ្ដាល មណ្ឌលគិរី ភ្នំពេញ រតនៈគិរី ស្ទឹងត្រែងនិងកែប) បានប្រមូលផល ១០០% លើផ្ទៃដីដែលបានដាំដុះ ។ ខេត្តក្រចេះ មានអត្រាទាបបំផុតត្រឹមតែ ៧៣,៨% នៃផ្ទៃដីស្រូវក្រអូបដែលត្រូវបានដាំដុះ ។

**កំណត់សម្គាល់**

- ផ្ទៃទឹក

អត្រាផ្ទៃដីបានប្រមូលផលធៀបនឹងផ្ទៃដីដាំដុះនៃស្រូវក្រអូប

- មិនមាន
- ≤ ៨០,០
- ៨០,១ - ៩០,០
- ៩០,១ - ៩៥,០
- > ៩៥,០

ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩

**ការបដិសេធ**

ព្រំប្រទល់រដ្ឋបាល និងឈ្មោះដែលបានប្រើនៅក្នុងផែនទីនេះមិនបញ្ជាក់ពីការយល់ព្រម ឬការទទួលស្គាល់ជាផ្លូវការណាមួយរបស់អង្គការសហប្រជាជាតិឡើយ ។

*តារាង ៣.២: អត្រាផ្ទៃដីដែលបានប្រមូលផលធៀបនឹងផ្ទៃដីដាំដុះនៃស្រូវក្រអូប*

| កូដខេត្ត | ឈ្មោះខេត្ត | គ្រួសារប្រកបរបរកសិកម្មមានផលិតកម្មស្រូវក្រអូប | ផ្ទៃដីដែលបានប្រមូល /ផ្ទៃដីដាំដុះ (x ១០០) |
|---|---|---|---|
| ០១ | បន្ទាយមានជ័យ | ២៤.៥៧៧ | ៩៧,៩ |
| ០២ | បាត់ដំបង | ២៦.៤០៩ | ៩២,៣ |
| ០៣ | កំពង់ចាម | ៩.៣១៧ | ៩៦,៦ |
| ០៤ | កំពង់ឆ្នាំង | ១៦.២៩៣ | ៩៨,៩ |
| ០៥ | កំពង់ស្ពឺ | ១៨.៩៥២ | ៩៨,០ |
| ០៦ | កំពង់ធំ | ១៤.១៦១ | ៩៣,៩ |
| ០៧ | កំពត | ៨.៧៦៦ | ៩៤,៤ |
| ០៨ | កណ្ដាល | ១៦២ | ១០០,០ |
| ០៩ | កោះកុង | ២០៤ | ៩៦,០ |
| ១០ | ក្រចេះ | ១.៩២០ | ៧៣,៨ |
| ១១ | មណ្ឌលគីរី | ១២ | ១០០,០ |
| ១២ | ភ្នំពេញ | ៣៣៩ | ១០០,០ |
| ១៣ | ព្រះវិហារ | ៧.៣៩៧ | ៩៦,១ |
| ១៤ | ព្រៃវែង | ២៧.៩៤៤ | ៩៧,៥ |
| ១៥ | ពោធិ៍សាត់ | ១០.៧២៤ | ៧៩,៧ |
| ១៦ | រតនៈគីរី | ៤៥៤ | ១០០,០ |
| ១៧ | សៀមរាប | ២៤.៥៨៥ | ៩៨,៤ |
| ១៨ | ព្រះសីហនុ | ០ | មិនមាន[i] |
| ១៩ | ស្ទឹងត្រែង | ១៥៣ | ១០០,០ |
| ២០ | ស្វាយរៀង | ៦.៥៣២ | ៩៩,៥ |
| ២១ | តាកែវ | ១៤.៨១៥ | ៩០,៤ |
| ២២ | ឧត្តរមានជ័យ | ៨.៦៩០ | ៩៦,៨ |
| ២៣ | កែប | ៩១ | ១០០,០ |
| ២៤ | ប៉ៃលិន | ០ | មិនមាន |
| ២៥ | ត្បូងឃ្មុំ | ៣.៥៧៩ | ៩៨,៩ |




ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មឆ្នាំ ២០១៩

[i] មិនមាន (N/A): ត្រូវបានប្រើសម្រាប់បញ្ជាក់ពីព័ត៌មាននៅក្នុងតារាងសំណួរមិនត្រូវបានអនុវត្ត ឬគ្មានចម្លើយ ។

# ផែនទី ៣.៣: ទិន្នផលស្រូវក្រអូប គិតជាគីឡូក្រាម / ហិកតា បែងចែកតាមខេត្ត




កម្ពុជា

ចំនួនគ្រួសារប្រកបរបរកសិកម្ម មានផលិតផលស្រូវក្រអូប : ២២៦.០៧៧

ផលិតផលស្រូវក្រអូបគិតជា គីឡូក្រាម/ ហិកតា : ២.៦១៣

មានលក្ខណ:ស៊ីគ្នានឹងផែនទី ៣.១ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ ស្ថិតក្នុងចំណោមខេត្ត ដែលមានទិន្នផលស្រូវក្រអូបខ្ពស់ជាងគេ (ខ្ពស់ជាង ៣ តោន / ហិកតា) ដោយឡែកភាគរយទិន្នផល ទាបជាងនេះ មាននៅខេត្តមណ្ឌលគិរី និងខេត្ត កណ្ដាល ខេត្តទាំងពីរនេះក៏ទទួលបានទិន្នផល ខ្ពស់ផងដែរ (ប្រមាណ ៤ តោន / ហិកតា) ។

## កំណត់សម្គាល់

- ផ្ទៃទឹក

ទិន្នផលស្រូវក្រអូប គិតជា គីឡូក្រាម / ហិកតា

- មិនមាន
- ≤ ២.០០០
- ២.០០១ - ២.៥០០
- ២.៥០១ - ៣.០០០
- > ៣.០០០

ប្រភព: អង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ ២០១៩

**ការបដិសេធ**
ព្រំប្រទល់រដ្ឋបាល និងឈ្មោះដែលបានប្រើនៅក្នុងផែនទីនេះមិនបញ្ជាក់ពីការយល់ព្រម ឬការទទួលស្គាល់ជាផ្លូវការណាមួយរបស់អង្គការសហប្រជាជាតិឡើយ ។

*តារាង ៣.៣: គ្រួសារប្រកបរបរកសិកម្មទទួលបានទិន្នន័យផលស្រូវក្រអូប*

| កូដខេត្ត | ឈ្មោះខេត្ត | គ្រួសារប្រកបរបរកសិកម្មទទួលបានទិន្នន័យផលស្រូវក្រអូប | ទិន្នផលស្រូវក្រអូប គិតជាគីឡូក្រាម/ ហិកតា |
|---|---|---|---|
| ០១ | បន្ទាយមានជ័យ | ២៤.៥៧៧ | ៣.២០១ |
| ០២ | បាត់ដំបង | ២៦.៤០៩ | ៣.៩១២ |
| ០៣ | កំពង់ចាម | ៩.៣១៧ | ២.៦៨៦ |
| ០៤ | កំពង់ឆ្នាំង | ១៦.២៩៣ | ២០៤៣ |
| ០៥ | កំពង់ស្ពឺ | ១៨.៩៥២ | ២.៥៤៣ |
| ០៦ | កំពង់ធំ | ១៤.១៦១ | ២.៦៧២ |
| ០៧ | កំពត | ៨.៧៦៦ | ២.០១៩ |
| ០៨ | កណ្ដាល | ១៦២ | ៤.០៥៥ |
| ០៩ | កោះកុង | ២០៤ | ២.៥៣៨ |
| ១០ | ក្រចេះ | ១.៩២០ | ២.០២១ |
| ១១ | មណ្ឌលគិរី | ១២ | ៣.៩៧៣ |
| ១២ | ភ្នំពេញ | ៣៣៩ | ២.១៣២ |
